# របាយការណ៍ប្រចាំត្រីមាសទី ១ ឆ្នាំ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម

## I. សេចក្តីផ្តើម

### 1. ស្ថានភាពភូមិសាស្ត្រ ខេត្តកំពង់ចាម

ខេត្តកំពង់ចាម ស្ថិតនៅដែនដីភាគខាងកើតប្រទេសកម្ពុជា ដែលមានចម្ងាយ ១២៤គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ខេត្តក៏មានផ្លូវជាតិសំខាន់ៗឆ្លងកាត់ដូចជា ផ្លូវជាតិលេខ 6A ផ្លូវជាតិលេខ 7 ដែលមានព្រំប្រទល់ខាងជើងជាប់ខេត្តកំពង់ធំ និងខេត្តក្រចេះ ខាងត្បូងជាប់ខេត្តព្រៃវែង ខេត្តកណ្តាល ខាងកើតជាប់ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ ខាងលិចជាប់ខេត្តកំពង់ឆ្នាំង ។

បច្ចុប្បន្នខេត្តកំពង់ចាមចែកចេញជា ស្រុក-ក្រុង ឃុំ-សង្កាត់ និងភូមិរដ្ឋបាល ដែលមានក្រុងចំនួន ០១ក្រុង មានសង្កាត់ ០៤សង្កាត់ និងស្រុកចំនួន ០៩ស្រុក មានឃុំចំនួន ១០៥ឃុំ ស្មើនឹង ៩១៦ភូមិ ។

ខេត្តកំពង់ចាមមានផ្ទៃដីសរុប ៤៥៤៨,០៩គ.ម$^2$ ហើយមានអំណោយផលធម្មជាតិយ៉ាងល្អប្រសើរដល់ដំណាំកសិកម្ម ដំណាំស្បៀង កសិឧស្សាហកម្មផងដែរ ។ ខេត្តកំពង់ចាម មានប្រជាពលរដ្ឋសរុប ១.០៩៧.០៨៥នាក់ ចំនួនស្ត្រីសរុប ៥៦២.០៨៥នាក់ ចំនួនគ្រួសារសរុប ២៥១.៤៥៨គ្រួសារ ដង់ស៊ីតេ ២៤១នាក់/គ.ម$^2$ ប្រជាកសិករប្រកបមុខរបរកសិកម្មចំនួន ៨0% មុខរបរសិប្បកម្ម 0.៨% សេវាកម្ម ១៦% មុខរបរមិនច្បាស់លាស់ (ចម្រុះ)៣.២0% ។

### 2. ស្ថានភាពរបស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានបង្កើតឡើងនៅឆ្នាំ១៩៩៤ រហូតដល់សព្វថ្ងៃមានការិយាល័យ ២០ ហើយចែកចេញជា ១០ការិយាល័យថ្នាក់ខេត្ត និង ១០ការិយាល័យថ្នាក់ស្រុក-ក្រុង ដោយមានមន្ត្រីសរុបចំនួន ៧២នាក់ ក្នុងនោះមានស្រីចំនួន ២០នាក់ ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ដឹកនាំដោយប្រធានមន្ទីរ ១រូប អនុប្រធានមន្ទីរ ០៤រូប និងប្រធាន-អនុប្រធានការិយាល័យមន្ទីរ និងថ្នាក់ស្រុកចំនួន ៦៤នាក់ ។

## II. សកម្មភាពតាមការិយាល័យនីមួយៗថ្នាក់ខេត្ត

1) ការងាររដ្ឋបាល និងបុគ្គលិក

បច្ចុប្បន្នមន្ទីរមានបុគ្គលិកក្របខ័ណ្ឌសរុបចំនួន ៧២នាក់ /ស្ត្រី ២០នាក់ គ្រប់គ្រងដោយប្រធានមន្ទីរ ០១រូប ទទួលបន្ទុកក្តាប់រួម និងអនុប្រធានមន្ទីរចំនួន ០៤រូប ក្នុងនោះមានស្ត្រី ០១រូប ។

- ការិយាល័យទាំង ១០ មានបុគ្គលិកសរុប ៤៤នាក់/ស្ត្រីមាន ១២នាក់ ។
- ការិយាល័យអភិវឌ្ឍន៍ជនបទក្រុង និងស្រុកមានបុគ្គលិកសរុបចំនួន ២៨នាក់/ ស្ត្រីចំនួន ០៩នាក់ ។
- ធ្វើលិខិតចេញបានចំនួន ១៣១ច្បាប់ និងទទួលលិខិតចូលចំនួន ១៥៦ច្បាប់ ។
- បានរៀបចំបញ្ជីវត្តមានប្រចាំថ្ងៃ ចំពោះមន្ត្រីការិយាល័យថ្នាក់ខេត្ត ។
- ធ្វើរបាយការណ៍ប្រចាំត្រីមាសទី១ ជូនសាលាខេត្ត និងក្រសួងទៀងទាត់រៀងរាល់ប្រចាំខែ ។

2) ការងារគណនេយ្យ និង ហិរញ្ញវត្ថុ

| ជំពូក | បរិយាយ | ស្ថានភាពឥណទានគិត (៛) | បណ្តាខែមុន | ចំណាយក្នុងគ្រា | ចំណាយបូកយោង | សមតុល្យ |
|---|---|---|---|---|---|---|
| ៦០ | ការទិញ | 180,800,000 | | 5,637,220 | 5,637,220 | 175,162,780 |
| ៦១ | សេវាខាងក្រៅ | 708,700,000 | | 48,620,000 | 48,620,000 | 660,080,000 |
| ៦៤ | បន្ទុកបុគ្គលិក | 686,200,000 | | 136,978,750 | 136,978,750 | 549,221,250 |
| **សរុប** | | 1,575,700,000 | | 191,235,970 | 191,235,970 | |

3) ការងារផែនការ និងស្ថិតិ

- រៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១៥-២០១៧ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ជាមួយការិយាល័យហិរញ្ញវត្ថុ ។
- ចូលរួមកសាងផែនការអភិវឌ្ឍន៍រយៈពេល ០៥ឆ្នាំ ឆ្នាំ២០១៥-២០១៩ និងកម្មវិធីវិនិយោគ ០៣ឆ្នាំ រំកិល ២០១៥-២០១៧ របស់រដ្ឋបាលសាលាខេត្តកំពង់ចាម ។
- រៀបចំប្រជុំពិភាក្សា និងការងារធ្វើបច្ចុប្បន្នភាពសៀវភៅផែនការត្រៀមបង្ការឆ្លើយតបគ្រោះមហន្តរាយឆ្នាំ ២០១៥ ។

**អធិការកិច្ច**

- ថ្ងៃទី ២៤-២៥ ខែធ្នូ ឆ្នាំ២០១៤ គណៈប្រតិភូអធិការកិច្ចក្រសួងអធិការកិច្ច និងហិរញ្ញវត្ថុដឹកនាំដោយ ឯកឧត្តម វី រដេជ្ជ ជាប្រធានគណៈប្រតិភូចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុ ការិយបរិច្ឆេទ ឆ្នាំ ២០១៣-២០១៤ ការគ្រប់គ្រងចំណូល-ចំណាយថវិកាមូលធន ថវិកាវិនិយោគ និងថវិកាវិនិយោគបុរេប្រទាន ។
- ថ្ងៃទី ២៣-២៤ ខែកុម្ភៈ ឆ្នាំ២០១៥ គណៈប្រតិភូអធិការកិច្ចក្រសួងអធិការកិច្ច ក្រសួងទំនាក់ទំនងជាមួយសភា រដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដឹកនាំដោយលោក អួន ម៉េងឈាន់ ជាប្រធានគណៈប្រតិភូចុះធ្វើអធិការកិច្ច លើការងារគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ការិយបរិច្ឆេទឆ្នាំ ២០១៤ បណ្តាឆ្នាំបន្ទាប់ ។

**កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ**

- ប្រធាន-អនុប្រធានមន្ទីរ និងមន្ត្រីរាជការមួយចំនួន បានចូលរួមប្រជុំផ្សេងៗចំនួន ១២៩លើក ។
- ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលចតុមុខ រាជធានីភ្នំពេញ ។
- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមផ្សព្វផ្សាយសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និងទិសដៅការងារឆ្នាំ ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលាខេត្តកំពង់ចាម ។
- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមសិក្ខាសាលាបញ្ចប់កម្មវិធី ផ្នែកសុខភាពអាហាររូបត្ថម្ភបំណិនជីវិត និងអនាម័យ ក្រោមគម្រោងឧបត្ថម្ភស្បៀងបន្ទាន់-ហិរញ្ញប្បទានបន្ថែម នៅសាលាខេត្តកំពង់ធំ ។

## III. សកម្មភាពតាមវិស័យ

1. ការិយាល័យផ្លូវលំជនបទ

ការិយាល័យផ្លូវលំជនបទក្នុងត្រីមាសទី១នេះ មន្ត្រីជំនាញនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានចុះសិក្សាផ្លូវបេតុងរបស់គម្រោង (ADB) RRIP បានចំនួន ០៣ខ្សែ ប្រវែង ៤៥.២៥គ.ម ស្ថិតនៅស្រុកកំពង់សៀម និងស្រុកកោះសូទិន ខេត្តកំពង់ចាម មានដូចខាងក្រោម÷

- សិក្សាផ្លូវបេតុងប្រវែង ១១.៥៥០គ.ម ស្ថិតនៅឃុំសំរោង ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។
- សិក្សាផ្លូវបេតុងប្រវែង ១៤.៧៨០គ.ម ស្ថិតនៅឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។
- សិក្សាផ្លូវបេតុងប្រវែង ១៨.៩២០គ.ម ស្ថិតនៅឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

**១– ការងារសាងសង់ផ្លូវអនុវត្តដោយគម្រោង RIP**

- ផ្លូវដីក្រាលកំទិចថ្មភ្នំប្រវែង ១.៨៣២គ.ម និងស្ពាន ០១កន្លែង ប្រវែង ២០ម៉ែត្រ ស្ថិតនៅឃុំកោះរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម លទ្ធផលសម្រេចបាន ៥០% ។
- ផ្លូវដីក្រាលគ្រួសក្រហមប្រវែង ៣.៩៣៩គ.ម ដែលស្ថិតនៅឃុំស្ដើងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម លទ្ធផលសម្រេចបាន ៥០% ។
- ផ្លូវភ្នំ ០១កន្លែង ដែលសាងសង់ដោយគម្រោង RIP ស្ថិតនៅឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម លទ្ធផលសម្រេចបាន ៤០% ។

**២– ការងារសាងសង់របស់គម្រោង ADB ទឹកជំនន់**

- ផ្លូវឆារខ្សាច់ប្រវែង ៦.៧០០ គ.ម ស្ថិតនៅឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម លទ្ធផលសម្រេចបាន ១០០% ។

2. <u>ការងារផ្គត់ផ្គង់ទឹកស្អាតជនបទ</u>

ការិយាល័យផ្គត់ផ្គង់ទឹកជនបទ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៥ បានធ្វើផែនការដូចខាងក្រោម÷

**១–** ក្នុងខែមករានេះ បានចុះសិក្សាទីតាំងសម្រាប់ជីកអណ្តូងអាហ្វ៊ីដេស ចំនួន ១២អណ្តូង ក្នុងស្រុក÷

- ស្រុកចំការលើចំនួន ០២អណ្តូង
- ស្រុកព្រៃឈរចំនួន ០៧អណ្តូង
- ក្រុងកំពង់ចាមចំនួន ០១អណ្តូង
- ស្រុកកោះសូទិនចំនួន ០២អណ្តូង

❖ ចុះសិក្សាទីតាំងអាងត្រង់ទឹកភ្លៀងចំណុះ ៣៥ម៣ ចំនួន ០២អាង ស្ថិតនៅស្រុក÷

- ស្រុកចំការលើចំនួន ០១អាង
- ស្រុកព្រៃឈរចំនួន ០១អាង

❖ ចុះសិក្សាទីតាំងជួសជុលអណ្តូងស្នប់ចំនួន ៣៨អណ្តូង ស្ថិតនៅស្រុកបាធាយ ខេត្តកំពង់ចាម

❖ ចុះ សិក្សាទីតាំងស្តារប្រឡាយប្រវែង ១,៥០០គ.ម ស្ថិតនៅស្រុកកោះសូទិន ខេត្តកំពង់ចាម

**២–** ក្នុងខែកុម្ភៈ បានស្តារអណ្តូងគ្រោះមហន្តរាយ គាំទ្រដោយអង្គការយូនីសេហ្វ ចំនួន ២៥អណ្តូង ក្នុងស្រុក÷

- ស្រុកកោះសូទិន ជួសជុលអណ្តូងអាហ្វ៊ីដេស ចំនួន ០៤អណ្តូង
- ស្រុកកំពង់សៀម ជួសជុលអណ្តូងអាហ្វ៊ីដេស ចំនួន ១០អណ្តូង
- ស្រុកកងមាស ស្តារ និងជួសជុលអណ្តូងអាហ្វ៊ីដេស ចំនួន ១១អណ្តូង
- និងបញ្ចូលទិន្នន័យតាមប្រព័ន្ធទូរស័ព្ទចល័ត
- ធ្វើតេស្តប៉ារ៉ាម៉ែត្រ ០៨មុខ បានចំនួន ៥០អណ្តូង ស្ថិតនៅស្រុកកំពង់សៀម ស្រុកកោះសូទិន ។

❖ ផ្នែកគ្រោះមហន្តរាយ គាំទ្រដោយអង្គការយូនីសេហ្វ បានធ្វើការផ្លាស់ប្តូរអណ្តូងស្នប់ N°6 ថ្មី បានចំនួន ១០អណ្តូង ស្ថិតក្នុងស្រុក÷

- ស្រុកកោះសូទិន ឃុំមហាលាភចំនួន 	០២អណ្តូង
- ស្រុកកងមាស ឃុំព្រែកក្របៅចំនួន 	០៨អណ្តូង

❖ កម្មវិធីបន្សុទ្ធទឹក គាំទ្រដោយអង្គការយូនីសេហ្វ បានធ្វើការតាមដានគ្រួសារដែលផឹកទឹកខ្វះអនាម័យ ធ្វើការអប់រំអោយផ្លាស់ប្តូរទម្លាប់ផឹកទឹកមានសុវត្ថិភាព ស្ថិតនៅស្រុកកំពង់សៀម ឃុំគគរ បានចំនួន ៩០ គ្រួសារ ។

❖ សហការជាមួយនាយកដ្ឋានសុខភាពជនបទ គាំទ្រដោយអង្គការយូនីសេហ្វ បានចុះសម្ភាសន៍អ្នកលក់ទឹកឯកជនតាមផ្ទះ ដើម្បីពង្រឹងសមត្ថភាពធ្វើអោយទឹកស្អាតបានចំនួន ២៨ស្ថានីយ ស្ថិតក្នុងស្រុក÷

- ស្រុកស្រីសន្ធរចំនួន 	១៣ស្ថានីយ
- ស្រុកកងមាសចំនួន 	០៣ស្ថានីយ
- ស្រុកកោះសូទិនចំនួន 	៧ស្ថានីយ
- ស្រុកកំពង់សៀមចំនួន 	០៥ស្ថានីយ

❖ ចុះសម្ភាសន៍រក X Y (G.P.S) អណ្តូងតាមគ្រួសារបានចំនួន ១២៩គ្រួសារ ស្ថិតក្នុងស្រុក÷

| | | | |
|---|---|---|---|
| - ស្រុកកងមាស | ឃុំរការ | ចំនួន | ៣១គ្រួសារ |
| | ឃុំខ្មៅ | ចំនួន | ៣០គ្រួសារ |
| | ឃុំព្រែកកុយ | ចំនួន | ០៩គ្រួសារ |
| - ស្រុកស្រីសន្ធរ | ឃុំឬស្សីស្រុក | ចំនួន | ៥៨គ្រួសារ |
| | ឃុំកោះអណ្តែត | ចំនួន | ០១គ្រួសារ |

- ក្នុងចំនួន ១២៩គ្រួសារ អ្នកដែលនៅប្រើប្រាស់អណ្តូងផ្ទាល់ ឬអ្នកប្រើប្រាស់ជាប្រចាំមានតែចំនួន ១៨គ្រួសារ ប៉ុណ្ណោះ ក្រៅពីនោះគឺ មានប្រើប្រាស់ម្តងម្កាល ។

3. <u>ការងារថែទាំសុខភាពជនបទ</u>

- ចូលរួមកិច្ចប្រជុំនៅOFFICE UNICEF ស្តីពី គំរូប្លង់អណ្តូងដែលត្រូវជួសជុលស្តារឡើងវិញ ក្រោយទឹកជំនន់ ។
- ចូលរួមធ្វើទិវាថ្នាក់ឃុំ ស្តីពី ការគ្រប់គ្រង និងលើកកម្ពស់អនាម័យជនបទ នៅស្រុកកងមាស ខេត្តកំពង់ចាម ។
- ចុះបើកវគ្គបណ្តុះបណ្តាលកម្មវិធីទឹកស្អាត និងអនាម័យតាមសាលារៀនចំនួន ១០សាលា មានអ្នកចូលរួមបានចំនួន ១៩៦នាក់/ ស្រី ៨០នាក់ ។
- ចុះសង្កេតមើលការបំផុសអនាម័យបន្តពីគ្រូទៅសិស្ស មានលោកគ្រូ អ្នកគ្រូ ចូលរួម ៤០នាក់/ ស្រី ១៨នាក់ ស្មើនឹង ១០សាលា សិស្សានុសិស្សចំនួន ៧៣៦នាក់/ ស្រី ៣៨២នាក់ ក្នុងមានស្រុកកំពង់សៀម ស្រុកកោះសូទិន ស្រុកកងមាស និងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។
- ចុះបំផុសអនាម័យតាមសាលាដល់សិស្សចំនួន ១០សាលា ចំនួនគ្រូ ៤០នាក់/ ស្រី ១៥នាក់ និងសិស្សចំនួន ៧៣៦ នាក់/ ស្រី ៣៨២នាក់ ស្មើនឹង១០ឃុំ ស្មើ ៤ស្រុក ។
- ចុះពិនិត្យ និងវាយតម្លៃអនាម័យតាមសាលាចំនួន ១០សាលា ស្មើនឹង ១០ឃុំ មាន ៤ស្រុក មានគ្រូចូលរួម ចំនួន ២០ នាក់/ ស្រី ០៩នាក់ ។ ការវាយតម្លៃជារួមឃើញថា តាមសាលាមានកំណើនអនាម័យល្អប្រសើរច្រើន ។
- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមប្រជុំការងារប្រចាំខែមករា ឆ្នាំ២០១៥ និងទិសទៅបន្ត ។
- ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៥ ចូលរួមប្រជុំផ្សព្វផ្សាយពីអនាម័យដល់ប្រជាពលរដ្ឋក្រ១ +ក្រ២ ជាមួយអង្គការលោកខាងលិច និងជួបលោកខាងកើត ។

- ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៥ ចុះផ្សព្វផ្សាយអនាម័យដល់ប្រជាពលរដ្ឋក្រ១+ក្រ២ នៅភូមិប្រាសាទ ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម មានអ្នកចូលរួម ២៤នាក់ ស្រុក ២០នាក់ ។
- ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៥ បានចុះស្រង់របាយការណ៍បង្គន់ចាក់ទឹកចំនួន ៨៣៦៥បង្គន់ និងបង្គន់ចាក់ផេះចំនួន ២៨១បង្គន់ ស្ថិតនៅស្រុកកងមាស ខេត្តកំពង់ចាម ។

4. <u>ការងារអភិវឌ្ឍន៍សហគមន៍ជនបទ</u>

- ថ្ងៃទី ១០-១៥ ខែកុម្ភៈ ឆ្នាំ២០១៥ ចុះផ្សព្វផ្សាយពីអនាម័យ នៅស្រុកព្រៃឈរ ។
- ចុះតាមដាន និងពង្រឹងសម្ថភាព(គ.អ.ភ) បានចំនួន ០៣លើក ក្នុងភូមិគោលដៅចំនួន ១៥ភូមិ ឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ។
- ថ្ងៃទី ១៦-២០ ខែកុម្ភៈ ឆ្នាំ២០១៥ ចុះតាមដាន និងពង្រឹងសម្ថភាព (គ.អ.ភ) បានចំនួន ០៥ភូមិ ក្នុងឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ។
- ថ្ងៃទី ២៣-២៧ ខែកុម្ភៈ ឆ្នាំ២០១៥ ចុះតាមដាន និងពង្រឹងសម្ថភាព (គ.អ.ភ) បានចំនួន ០៥ភូមិ ក្នុងឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ។

5. <u>ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ</u>

**១- គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ**

| | | |
|---|---|---|
| - ស្រុកចំនួន ០៤ស្រុក | ឃុំចំនួន ១៤ឃុំ | ភូមិចំនួន ៤០ភូមិ |
| - អតិថិជនសរុបចំនួន ៨៥៩នាក់ | ស្រីចំនួន ៧២០នាក់ | |
| - ក្រុមចំនួន | ៨៦៩ក្រុម | |
| - ប្រាក់ដើមឱ្យខ្ចីចំនួន | ៥៥៩,៣០០,០០០រៀល | |
| - ប្រាក់ដើមសងចំនួន | ៥៤៩,០០៣,៩០០រៀល | |
| - ប្រាក់ការសងចំនួន | ៨៥,៥៤៤,៥០០រៀល | |
| - ប្រាក់ដើមនៅជំពាក់ចំនួន | ១,៣៩៦,១៥០,០០០រៀល | |

**២- គម្រោងឥណទានកូរ៉េ**

| | | |
|---|---|---|
| - ស្រុកចំនួន ០១ស្រុក | ឃុំចំនួន ០១ឃុំ | ភូមិចំនួន ០៤ភូមិ |
| - អតិថិជនសរុបចំនួន ២៤៤នាក់ | ស្រីចំនួន ១៨៩នាក់ | |
| - ក្រុមចំនួន | ៧៩ក្រុម | |
| - ប្រាក់ដើមឱ្យខ្ចីចំនួន | ៧១,១០០,០០០រៀល | |
| - ប្រាក់ដើមសងចំនួន | ៦០,៩៧៩,២០០រៀល | |
| - ប្រាក់ការសងចំនួន | ១៣,៣៣២,៦០០រៀល | |
| - ប្រាក់ដើមនៅជំពាក់ចំនួន | ២១៤,៨១៨,០០០រៀល | |

6. <u>ការងារអភិវឌ្ឍន៍បណ្តុះបណ្តាល និងស្រាវជ្រាវ</u>

ដោយមានការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីបង្កើនជំនាញជូនដល់ប្រជាពលរដ្ឋក្រីក្រ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានចាប់ផ្តើមបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញមូលដ្ឋាន សំដៅឱ្យយុវជន យុវនារីក្រីក្រ កំព្រា ដែលមិនអាចមានលទ្ធភាពបន្តការសិក្សាទៅមុខទៀត ដើម្បីឱ្យពួកគេមានជំនាញមួយពិតប្រាកដ ។ ហើយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញមូលដ្ឋាន បានធ្វើការផ្សព្វផ្សាយទៅដល់ភូមិ-ឃុំ តាមរយៈមន្ត្រីការិយា

ល័យស្រុក-ក្រុងទាំង ០៩ស្រុក ០១ក្រុង ខេត្តកំពង់ចាម និងបានផ្សព្វផ្សាយតាមវិទ្យុខេត្ត ដើម្បីជ្រើសរើសសិស្សចូលរៀនតាមមុខជំនាញ ។

❖ ការងារបណ្តុះបណ្តាលក្នុងមជ្ឈមណ្ឌល

ក្នុងខែមករា និងខែមីនា ឆ្នាំ២០១៥ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តកំពង់ចាម បានធ្វើការចុះផ្សព្វផ្សាយជ្រើសរើសសិក្ខាកាមតាមភូមិ-ឃុំ ស្រុក-ក្រុង ក្នុងខេត្ត ដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ខេត្តកំពង់ចាម ដែលមានជំនាញដូចខាងក្រោម÷

- ជំនាញកុំព្យូទ័រការិយាល័យ
- ជំនាញជួសជុលទូរស័ព្ទ
- ជំនាញជួសជុលម៉ូតូ
- ជំនាញកែសម្ផស្ស និងអ៊ុតសក់

យោងតាមការចុះផ្សព្វផ្សាយនៅតាមមូលដ្ឋានកន្លងមក មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្តកំពង់ចាម នៅខែមីនា ឆ្នាំ២០១៥នេះ បានទទួលពាក្យសុំចូលរៀនវគ្គបណ្តុះបណ្តាលជំនាញបានចំនួន÷

| | | |
|---|---|---|
| - ជំនាញកុំព្យូទ័រការិយាល័យមានសិក្ខាកាមចំនួន | ១៤នាក់ | ស្រី ០៩នាក់ |
| - ជំនាញជួសជុលទូរស័ព្ទមានសិក្ខាកាមចំនួន | ០៤នាក់ | ស្រី ០នាក់ |
| - ជំនាញជួសជុលម៉ូតូមានសក្ខាកាមចំនួន | ០៤នាក់ | ស្រី ០នាក់ |
| - ជំនាញកែសម្ផស្ស និងអ៊ុតសក់មានសក្ខាកាមចំនួន | ០៤នាក់ | ស្រី ០៤នាក់ |
| - សរុប **មានសិក្ខាកាមចំនួន** | **៣១នាក់** | **ស្រី ១៨នាក់** |

❖ មន្ត្រីរាជការដែលកំពុងសហាការជាមួយអង្គការអន្តរជាតិ និងអង្គការជាតិ

| | |
|---|---|
| - គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម | ១៥នាក់ |
| - អង្គការ ADB | ០៦នាក់ |
| - អង្គការយូនីសេហ្វ (UNICEF) | ០៥នាក់ |
| - កម្មវិធី RIP | ០៤នាក់ |

❖ ការងារសហាការជាមួយអង្គការ NGOs

- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានសហការណ៍ជាមួយអង្គការដៃគូមួយចំនួន ដែលទទួលបានការគាំទ្រពីមូលនិធិអនាម័យសកល (Global Sanitation Fund) មានដូចជា៖ អង្គការ Plan, អង្គការទឹកភ្លៀង, អង្គការ SNV, អង្គការ NAS, អង្គការ CHED, អង្គការទឹកស្អាត ១០០១, អង្គការ Water SHED និងអង្គការ UNICEF អប់រំអនាម័យតាមសាលារៀន និងសហគមន៍មូលដ្ឋាន ។

❖ គម្រោងឧបត្ថម្ភស្បៀងបន្ទាន់

- ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៥ ចូលរួមសិក្ខាសាលាបញ្ចប់កម្មវិធីផ្នែកសុខភាពអាហារូបត្ថម្ភបំណិនជីវិត និងអនាម័យក្រោមគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ ហិរញ្ញប្បទានបន្ថែម នៅសាលាខេត្តកំពង់ធំ ។
- សិក្ខាសាលាបញ្ចប់គម្រោងអង្គការភ្លែន និងអង្គការដៃគូ ស្តីពី ការប្រតិបត្តិកម្មវិធីបំណិនជីវិត និងអាហារូបត្ថម្ភដល់មាតា និងទារកក្រោមគម្រោងឧបត្ថម្ភស្បៀងបន្ទាន់-ហិរញ្ញប្បទានបន្ថែម ។

❖ ការងារអង្គការយូនីសេហ្វ

- បានធ្វើពិធីប្រជុំថ្នាក់ឃុំអំពី ការប្រើប្រាស់ទឹកស្អាត ដែលស្ថិតនៅភូមិគគរ១ ភូមិគគរ២ ភូមិចំការសាសិប និងភូមិកំពង់ក្របី បាន ៤៨ក្រុម សរុប ១គ្រួសារ ។៣៨៣,
- បានធ្វើការបណ្តុះបណ្តាលប្រធានក្រុម និងក្រុមប្រឹក្សាឃុំ ដែលប្រើប្រាស់ទឹកស្អាតសរុប ៥១នាក់/ ស្រី ០៨នាក់ ។
- បានជួសជុលអណ្តូងស្នប់ ផ្ទីស្តារដោយគ្រោះមន្តរាយដែលគាំទ្រពីអង្គការយូនីសេហ្វ នៅសាលាបឋមសិក្សាអំបែងចេះ និងសាលាបឋមសិក្សាទន្សាយកោង ឃុំល្វេ ស្រុកកោះសូទិនបានចាក់សាប និងលើកខឿន ២ម៉ែត្រ កំពុងដំណើរការសាងសង់ និងផ្ទីស្តារជួសជុលអណ្តូងសហគមន៍ចំនួន ០៣អណ្តូង ភូមិគគ១ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។
- ជួសជុលអណ្តូងស្នប់ ផ្ទីស្តារដោយគ្រោះមហន្តរាយដែលគាំទ្រ ពីអង្គការយូនីសេហ្វចំនួន ២៥អណ្តូង ក្នុងនោះផ្ទីស្តារជួសជុលស្នប់អាហ្វ្រីដេស ១៥ លើកខឿនកម្ពស់ ២ម៉ែត្រ ចំនួន ៤ និងផ្ទីស្តារស្នប់លេខ៦ ចំនួន ១០អណ្តូង ក្នុងនោះស្រុកកោះសូទិន បានចំនួន ០៤អណ្តូង លើកខឿនខ្ពស់ចំនួន ០១អណ្តូង ស្រុកកំពង់សៀម បានចំនួន ១០អណ្តូង លើកខឿនខ្ពស់បានចំនួន ០១អណ្តូង ស្រុកកងមាសចំនួន ១១អណ្តូង លើកខឿនបានចំនួន ២អណ្តូង និងអណ្តូងស្នប់លេខ៦ ចំនួន ៨ លើកខឿនបានចំនួន ០២អណ្តូង ។
- ថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៥ មានកិច្ចប្រជុំប្រចាំត្រីមាសលើកទី២ ជាមួយអ្នកពាក់ព័ន្ធគម្រោងក្រោមហិរញ្ញប្បទាន របស់អង្គការយូនីសេហ្វ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។

❖ ការងារយេនឌ័រ

- ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៥ លោក អ៊ឹង ចាន់ណារ៉េត អនុប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំប្រចាំខែមករា របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត នៅសាលាខេត្តកំពង់ចាម ។
- ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៥ លោកប្រធានមន្ទីរ លោកស្រីអនុប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំលើកទី៣៣ របស់គណៈកម្មាធិការសម្របសម្រួលគម្រោងសាកល្បង នៅមន្ទីរកិច្ចការនារី ខេត្តកំពង់ចាម ។
- ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៥ លោកប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំលើកទី៦ របស់គណៈកម្មាធិការសម្របសម្រួលរួម (JCC) នៅសណ្ឋាគារភ្នំពេញ ។
- ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៥ លោក អ៊ឹង ចាន់ណារ៉េត អនុប្រធាន ចូលរួមកិច្ចប្រជុំប្រចាំខែមករា របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត នៅសាលាខេត្តកំពង់ចាម ។

7. <u>ការិយាល័យជនជាតិដើមភាគតិច</u> (គ្មានសកម្មភាព)

## IV. <u>ទិសដៅផែនការឆ្នាំ ២០១៥</u>

មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម បានខិតខំប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នជាតិ អង្គការ សហគមន៍នានា ឱ្យមានភាពកាន់តែប្រសើរឡើងដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋមានលក្ខណៈសមស្របពីមួយថ្ងៃទៅមួយថ្ងៃ និងស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ។

## V. <u>បញ្ហាប្រឈម</u>

ស្របតាមសមិទ្ធផលដែលទទួលបានពីអនុវត្តន៍ការងារក្នុងឆ្នាំកន្លងមក មន្ទីរបានកត់សម្គាល់ឃើញថា មានការប្រឈមមួយចំនួននៅពេលចុះអនុវត្តន៍ការងារដូចជា ÷

- ការពង្រឹងធនធានមនុស្សដល់មន្ត្រីមន្ទីរនូវមានកម្រិត ព្រោះការបណ្តុះបណ្តាលជំនាញបច្ចេកទេស នៅពុំទាន់បានសមស្របតាមផ្លូវការ ។
- ការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត ក្នុងការថែទាំសមិទ្ធផលដែលបានផ្តល់ការយល់ដឹងរបស់ប្រជាពលរដ្ឋ លើការថែទាំសុខភាព និងអនាម័យ អប់រំផ្សព្វផ្សាយបានទូលំទូលាយ ការផ្លាស់ប្តូរទម្លាប់របស់សហគមន៍នៅមានភាពយឺតយ៉ាវ ។

VI. **<u>សន្និដ្ឋាន</u>**

យោងតាមរបាយការណ៍អនុវត្តន៍គោលនយោបាយយុទ្ធសាស្រ្ត និងផែនការអភិវឌ្ឍន៍បានបង្ហាញឱ្យឃើញថា ដើម្បីអនុវត្តន៍ផែនការអភិវឌ្ឍន៍ជនបទ បានសម្រេចលុះត្រាតែយើងបានអនុវត្តនូវសកម្មភាពដូចខាងក្រោម÷

- ធ្វើអោយមានសកម្មភាពឡើងវិញនូវគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ដែលត្រូវបានចំណាត់ថ្នាក់ជាអាទិភាពនៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជនបទ ។
- ការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា សំណង់ធារាសាស្រ្ត ផ្លូវជនបទ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។ ដោយអនុវត្តន៍គោលនយោបាយយុទ្ធសាស្រ្ត និងផែនការអភិវឌ្ឍន៍ជនបទ របស់មន្ទីរបានបង្ហាញឱ្យឃើញថា ខេត្តកំពង់ចាម ទទួលបានការអភិវឌ្ឍន៍ដូចជា ស្ពាន និងផ្លូវលំជនបទខ្វាត់ខ្វែងសម្រាប់ប្រជាពលរដ្ឋធ្វើចរាចរណ៍ក្នុងការដឹកនាំកសិផលដែលជាកត្តា ធ្វើអោយប្រជាពលរដ្ឋកាន់តែជិតរវាងជនបទ និងទីប្រជុំជន ។ ធ្វើឱ្យប្រជាជនមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ ជាពិសេសធ្វើអោយយល់ដឹងពីសុខភាព និងអនាម័យតាមរយៈការអប់រំផ្សព្វផ្សាយ និងប្រើប្រាស់បង្គន់អនាម័យ ។

សរុបសេចក្តីមក យើងឃើញថា ការអនុវត្តន៍គោលនយោបាយ និងផែនការអភិវឌ្ឍន៍ជនបទ បានចូលរួមអនុវត្តន៍ឱ្យបានជោគជ័យនូវយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ អាណត្តិទី៥ និងគោលនយោបាយ ស្តីពី ការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង សំដៅលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋតាមរយៈ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ធ្វើឱ្យប្រជាពលរដ្ឋមានល័ក្ខខ័ណ្ឌល្អប្រសើរក្នុងជីវភាពរស់នៅ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ច ។

**ប្រធានមន្ទីរ**